# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអេស្កាប់ ដែលហៅកាត់ថា គ.ជ.អ.ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ដើម្បីសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។

## ជំពូកទី ២

## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការជាតិអេស្កាប់មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - ឥស្សរជនជាន់ខ្ពស់មួយរូប | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - តំណាងស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ៣.-**

គណៈកម្មាធិការជាតិអេស្កាប់ ដឹកនាំដោយប្រធានមានឋានៈចាប់ពីទេសរដ្ឋមន្ត្រីឡើងទៅ ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ។ សមាសភាពរបស់គណៈកម្មាធិការជាតិអេស្កាប់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា ៤.-**

គណៈកម្មាធិការជាតិអេស្កាប់មានតួនាទីដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវលើប្រធានបទសេដ្ឋកិច្ច និងសង្គមកិច្ច នៅអាស៊ី និងប៉ាស៊ីហ្វិក ដែលពាក់ព័ន្ធនឹងព្រះរាជាណាចក្រកម្ពុជា
- ធ្វើទំនាក់ទំនងជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ "UN-ESCAP" ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា
- សហការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ អង្គការជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីដំណើរការការងារឱ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាព
- ស្វែងរកគម្រោង និងធនធាន ដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិអេស្កាប់មានភារកិច្ចដូចខាងក្រោម ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជូនរាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយបណ្ដាក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការជាតិ អន្តរជាតិនានា
- រៀបចំកិច្ចប្រជុំនានាជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ
- ចូលរួមប្រជុំថ្នាក់អន្តរជាតិនានា តាមការចាត់តាំងរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន

## ជំពូកទី ៤
## ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិអេស្កាប់

**មាត្រា ៦.-**

គណៈកម្មាធិការជាតិអេស្កាប់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអគ្គលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ជាជំនួយការ ។

មាត្រា ៨.-

សមាជិកគណៈកម្មាធិការជាតិអេស្កាប់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

មាត្រា ៩.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិអេស្កាប់ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ១០.-

គណៈកម្មាធិការជាតិអេស្កាប់មានសិទ្ធិប្រើប្រាស់ត្រាជាច់ដោយឡែក។

មាត្រា ១១.-

គណៈកម្មាធិការជាតិអេស្កាប់មានទីតាំងស្ថិតនៅទីស្ដីការគណៈរដ្ឋមន្ត្រី។

មាត្រា ១២.-

គណៈកម្មាធិការជាតិអេស្កាប់មានកញ្ចប់ថវិកាជាឧបសម្ព័ន្ធថវិការបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

គណៈកម្មាធិការជាតិអេស្កាប់មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ១៤.-

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ១៥.-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩ល.០១០១.០២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩

លេខ : ៣០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ចិនកេន